Panasonic

- សូមអានការណែនាំពីរបៀបដំឡើងដោយប្រុងប្រយ័ត្នមុនពេលដំឡើង និងការណែនាំអំពីដំណើរការមុនពេលប្រើប្រាស់វា។
- ព័ត៌មានលម្អិតនៃម៉ាស៊ីន អាចផ្លាស់ប្តូរដោយពុំបានជម្រាបជូនមុន។
- មាតិកានៃសៀវភៅកាតាឡុករៀបចំនៅក្នុងខែធ្នូ 2019។
- ដោយសារការបោះពុម្ព ដូចនេះពណ៌ជាក់ស្តែងអាចស្រាលជាងរូបនៃការបង្ហាញ។
- ក្រាហ្វិកទាំងអស់ផ្តល់ជូនសម្រាប់តែប្រើប្រាស់នៅក្នុងកម្មវិធីនៃការរចនាប៉ុណ្ណោះ។

Do not add or replace refrigerant other than the specified type. Manufacturer is not responsible for the damage and deterioration in safety due to usage of other refrigerant.

អ្នកមានសិទ្ធិចែកចាយ

**សាខានៃ Panasonic Asia Pacific Pte. Ltd.**
មជ្ឈមណ្ឌលថៃទាំអតិថិជនផ្ទះលេខ 327-329 មហាវិថី ព្រះសីហនុ
សង្កាត់វាលវង់ ខណ្ឌ 7 មករា រាជធានីភ្នំពេញ ប្រទេសកម្ពុជា
លេខទូរស័ព្ទ៖ +855 2321 5503
អ៊ីម៉ែល៖ service@kh.panasonic.com

Panasonic Global Air Conditioner
Global Site : aircon.panasonic.com
PROClub : panasonicproclub.global
airconpanasonicglobal

AC-CMBA-C-2020

Panasonic

# ម៉ាស៊ីនត្រជាក់ផ្តល់នូវផាសុកភាពសម្រាប់គេហដ្ឋាន 2020/2021


Built-in Independent Air Purifier
Only 25W/Hour with cooling OFF



ELITE INVERTER
SKY SERIES



X-PREMIUM INVERTER
AERO SERIES

ជីវិតកាន់តែស្រស់ស្រាយ ពិភពលោកកាន់តែស្រស់ថ្លា

## ខ្យល់បរិសុទ្ធស្រស់ថ្លាសម្រាប់ជីវិត

# ខ្យល់បរិសុទ្ធស្រស់ថ្លាសម្រាប់ជីវិត

ខ្យល់បរិសុទ្ធ គឺចាំបាច់ណាស់សម្រាប់ការរស់នៅប្រកបដោយផាសុកភាព

ក្រុមហ៊ុន Panasonic យើងកំពុងនាំមកនូវការច្នៃប្រឌិតថ្មីៗ ដែលធ្វើឲ្យជីវិតមនុស្ស ជុំវិញពិភពលោករស់នៅប្រកបដោយផាសុកភាព និងមានសុខភាពល្អបរិបូរណ៍។

នេះជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់យើង ក្នុងការផ្តល់នូវខ្យល់បរិសុទ្ធស្រស់ថ្លា សម្រាប់ជីវិត។ ក្រុមហ៊ុន Panasonic ផ្តល់នូវដំណោះស្រាយខ្យល់បរិសុទ្ធកាន់តែ ធំទូលាយ និងប្រកបដោយស្តង់ដារច្បាស់លាស់សម្រាប់ការប្រើប្រាស់នៅទីកន្លែង ផ្សេងៗគ្នា  ដែលបានបែងចែកជា 4 ប្រភេទសំខាន់ៗ។


ផ្តល់នូវខ្យល់ត្រជាក់ស្រស់ស្រាយ



បន្សុទ្ធខ្យល់ឲ្យបរិសុទ្ធស្រស់ថ្លា

ខ្យល់បរិសុទ្ធស្រស់ថ្លាស្ថិតក្នុងដៃរបស់អ្នក


ផ្តល់នូវខ្យល់បរិសុទ្ធស្រស់ថ្លាដោយគ្មានការរំខាន

**យើងអាចកែច្នៃខ្យល់ឲ្យបរិសុទ្ធស្រស់ថ្លា**
**អ្នកក៏អាចកែប្រែជីវិតរស់នៅឲ្យកាន់តែល្អប្រសើរ**

## មាតិកា

# ការស្វែងយល់អំពី
# បញ្ហាគុណភាពខ្យល់បរិសុទ្ធនៅក្នុងគេហដ្ឋាន

រាល់ថ្ងៃនេះ ចៀសមិនផុតទេនឹងមានខ្យល់កខ្វក់ហើរចូលពីខាងក្រៅមកក្នុងផ្ទះរបស់យើងដោយមិនដឹងខ្លួន ដែលធ្វើបរិយាកាសក្នុងផ្ទះក្លាយជាបញ្ហាធ្ងន់ធ្ងរលើសពីអ្វីដែលយើងបានដឹង។

## បញ្ហាទូទៅជាមួយនឹងគុណភាពខ្យល់ក្នុងផ្ទះ




## បន្ទប់ទទួលភ្ញៀវ

តើអ្នកជួបប្រទះបញ្ហាខ្យល់ក្ដៅខ្លាំង នៅពេលអ្នកទៅដល់ផ្ទះមែនទេ ?
តើអ្នកមានអារម្មណ៍ថាមិនត្រជាក់ស្រស់ស្រាយ នៅពេលដែលមានមនុស្សច្រើនមកជប់លៀងនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់អ្នកមែនទេ ?




ខ្យល់ក្ដៅនឹងឡើងកម្ដៅធំនៅកន្លែងបិទជិត។ មនុស្សរួមចំណែកក្នុងការកើនឡើងកម្ដៅ និងសំណើមនៅក្នុងបរិយាកាស។

ភាពខុសគ្នារវាងកម្ពស់កុមារ និងមនុស្សពេញវ័យ ធ្វើឲ្យសុខភាពរបស់ពួកគេក៏ខុសគ្នាដែរមែនទេ ?




ជារៀងរាល់ថ្ងៃ ក្មេងដកដង្ហើមកៀកនឹងកម្រាលឥដ្ឋ និងគ្រឿងសង្ហារឹម។

## បន្ទប់គេង

ជាធម្មតា តើបន្ទប់មួយណាដែលអ្នកចំណាយពេលច្រើននៅពេលដែលអ្នកនៅផ្ទះ ?




ភាគច្រើនមនុស្សយើងចំណាយពេល៨ម៉ោង គេងក្នុងមួយថ្ងៃនៅក្នុងបន្ទប់គេង ដើម្បីក្រោកមកមានអារម្មណ៍ស្រស់ស្រាយនៅថ្ងៃបន្ទាប់។

## បន្ទប់សិក្សា

តើអ្វីខ្លះ ដែលរំខានដល់ការផ្ដោតអារម្មណ៍សិក្សាកូនរបស់អ្នក ?




សំឡេងរំខាន និងសីតុណ្ហភាពបន្ទប់ត្រជាក់ខ្លាំង ធ្វើឲ្យប៉ះពាល់ដល់ការផ្ដោតអារម្មណ៍សិក្សារបស់កូនអ្នក។

# ដំណោះស្រាយខ្យល់បរិសុទ្ធស្រស់ថ្លា សម្រាប់គេហដ្ឋាន

ដំណោះស្រាយខ្យល់បរិសុទ្ធស្រស់ថ្លាដ៏ពេញលេញ អាចបំពាក់នៅគ្រប់បន្ទប់នៅក្នុងផ្ទះរបស់អ្នក ជាមួយការប្រើប្រាស់ប្រភេទម៉ាស៊ីនត្រជាក់ខុសៗគ្នា ដូចជាកែច្នៃបន្ទប់ទទួលភ្ញៀវរបស់អ្នកទៅជាទីកន្លែងមួយដែលអ្នក និងគ្រួសាររបស់អ្នកស្នាក់នៅមានផាសុកភាព និងមានសុខភាពល្អ។




បច្ចេកវិទ្យានៃការរចនាខ្យល់បរិសុទ្ធស្រស់ថ្លារបស់ Panasonic ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវខ្យល់បរិសុទ្ធស្រស់ថ្លា ដែលអាចជួយអ្នករស់នៅមានផាសុកភាព។ យើងសូមណែនាំអ្នកនូវដំណោះស្រាយនៃការរចនាខ្យល់បរិសុទ្ធស្រស់ថ្លាដ៏ពេញលេញ ដើម្បីការរស់នៅស្រស់ស្រាយសប្បាយចិត្តរៀងរាល់ថ្ងៃ និងក្នុងឱកាសពិសេសៗរបស់អ្នក។

ផ្តល់នូវជីវិតរស់នៅប្រកបដោយផាសុកភាព សុខភាពល្អ និងកាន់តែមានសុភមង្គលនៅក្នុងគ្រួសារ។


បន្ទប់ទទួលភ្ញៀវ


បន្ទប់ទទួលទានអាហារ


បន្ទប់គេងរបស់មេគ្រួសារ


បន្ទប់សិក្សា

# ពេលវេលាដ៏មានតម្លៃនៅក្នុងបន្ទប់ ដ៏សំខាន់នៅក្នុងផ្ទះរបស់អ្នក

## ការដំឡើងម៉ាស៊ីនត្រជាក់

| បន្ទប់ទទួលភ្ញៀវ + បន្ទប់ទទួលទានអាហារ | បន្ទប់ទទួលទានអាហារ |
|---|---|
|  |  |
| 2.5HP X-PREMIUM INVERTER Single Split Type | 1.0HP X-PREMIUM INVERTER Single Split Type |
| AERO Series (XU Model) | AERO Series (XU Model) |




### បរិយាកាសបន្ទប់មិនល្អនាំឲ្យអ្នកមានអារម្មណ៍តប់ប្រមល់

- អ្នកមានអារម្មណ៍មិនល្អនៅក្នុងបន្ទប់ទទួលភ្ញៀវ នៅពេលដែលមានមនុស្សច្រើនចេញចូល និងបាននាំយកធូលី និងពពួកបាក់តេរីមេរោគផ្សេងៗពីខាងក្រៅដោយអ្នកមើលមិនឃើញនឹងភ្នែក។

# ដំណោះស្រាយខ្យល់បរិសុទ្ធ នៅក្នុងបន្ទប់ទទួលភ្ញៀវ + បន្ទប់ទទួលទានអាហារ

## ការបន្សុទ្ធខ្យល់ស្រស់ថ្លា


### ខ្យល់បរិសុទ្ធស្រស់ថ្លា

- សម្អាតល្អងធូលី( PM2.5 ) និងបង្ការអាឡែកហ្ស៊ី រួមទាំងលម្អងផ្កាដែលតោងជាប់តាមភ្ញៀវមកពីក្រៅ។


### បរិយាកាសស្រស់ថ្លាសម្រាប់កូនអ្នកលេងដោយរីករាយ

- កម្ចាត់ការលូតលាស់បាក់តេរី និងមេរោគដែលតោងជាប់នៅលើកម្រាលព្រំ និងគ្រឿងសង្ហារិមដូច្នេះក្មេងៗអាចលេងយ៉ាងរីករាយ ដោយឥតបារម្ភ។


### ទីកន្លែងសម្រាប់គ្រួសាររីករាយ

- បំបាត់ក្លិនមិនល្អក្រោយពេលចម្អិនអាហារ ក្លិនឈ្ងៀម និងក្លិនមិនល្អដូចជា ក្លិនបារី ឬក្លិនសត្វជាដើម។

## ចរន្តខ្យល់

### ខ្យល់ត្រជាក់លឿន សម្រាប់ឱកាសជួបជុំរបស់អ្នក

- ការបាញ់ខ្យល់ត្រជាក់លឿនធ្វើឲ្យអ្នកគ្រប់គ្នាមានអារម្មណ៍ត្រជាក់ភ្លាមៗ។



### ត្រជាក់ស្រស់ស្រាយសព្វកន្លែង នៅពេលមានមនុស្សតិចក្នុងបន្ទប់

- AEROWINGS បាញ់ខ្យល់ត្រជាក់សាយភាយពេញផ្ទៃបន្ទប់ ដោយស្វ័យប្រវត្តិ និងមិនធ្វើឲ្យត្រជាក់ខ្លាំងនៅពេលអ្នកបានកំណត់សីតុណ្ហភាពរួចជាស្រេច។

## ប្រសិទ្ធភាពខ្យល់ស្រស់ថ្លា


ផ្អែកលើការបង្ហាញក្រាហ្វិករបស់ថាមពលបញ្ចេញក្នុងពេលបញ្ចេញភាពត្រជាក់នៃម៉ាស៊ីនត្រជាក់ម៉ូដែល INVERTER PREMIUM 1.5HP ។

### ថាមពលបញ្ចេញខ្យល់ខ្លាំង សម្រាប់ការជួបជុំនៅទីតាំងខុសៗគ្នា

- អ្នកទទួលបានអារម្មណ៍រីករាយជាមួយសីតុណ្ហភាពថេរប្រកបដោយផាសុកភាព ដែលថាមពលបញ្ចេញខ្យល់ខ្លាំង ពី 0.92kW ទៅ 4.20kW ។


### អាចកែតម្រូវសីតុណ្ហភាពដោយស្វ័យប្រវត្តិជាមួយការគ្រប់គ្រងសីតុណ្ហភាពតាមស្ថានភាពជាក់ស្តែង។

- បច្ចេកវិទ្យា Inverter អាចផ្លាស់ប្តូរល្បឿននៃការបញ្ចេញធាតុត្រជាក់ ដែលធានាបាននូវសីតុណ្ហភាពត្រជាក់មួយដែលអ្នកបានកំណត់រួចរាល់។

# គេងលក់ស្កប់ស្កល់ និងភ្ញាក់ឡើងមានអារម្មណ៍ស្រស់ស្រាយ

## ការដំឡើងម៉ាស៊ីនត្រជាក់

| បន្ទប់គេងរបស់មេគ្រួសារ | បន្ទប់គេងកូន |
| --- | --- |
| 1.0HP ELITE INVERTER Single Split Type | 1.0HP X-PREMIUM INVERTER Single Split Type |
| SKY Series (VU Model) · nanoe TECHNOLOGY · AutoX · INVERTER · (CS-VU10UKH) | AERO Series (XU Model) · nanoe TECHNOLOGY · AutoX · INVERTER |

**ខ្យល់កខ្វក់ និងកំទេចកំទីល្អិតៗនៅជាប់កម្រាលពូក នៅក្នុងបន្ទប់គេងកក់ក្តៅរបស់អ្នក**

- ខ្យល់កខ្វក់នៅក្នុងបន្ទប់គេងអាចរំខានដល់ការគេងរបស់អ្នក។

# ដំណោះស្រាយខ្យល់បរិសុទ្ធ **នៅក្នុងបន្ទប់គេង**

## ការបន្សុទ្ធខ្យល់ស្រស់ថ្លា


**បន្ទប់មានខ្យល់ស្រស់ថ្លាធ្វើឲ្យអ្នកគេងលក់ស្រួល**

- សម្អាតល្អងធូលីតូចៗ ( PM2.5 ) នៅក្នុងខ្យល់សម្រាប់ការគេងលក់ស្រួល




**សម្អាតកម្រាលពូក និងក្រណាត់ផ្សេងៗ**

- nanoe™ X ជ្រាបចូលជ្រៅក្នុងសាច់ក្រណាត់ ដើម្បីបំបាត់ក្លិនអាក្រក់ និងកម្ចាត់សារធាតុពុលទាំងឡាយ។


**គេងលក់ស្រួលនៅក្នុងបរិយាកាសដែលមានសំណើមស្រស់ថ្លា**

- nanoe™ X ផ្តល់សំណើមដល់ស្បែក និងសរសៃសក់រឹងមាំ ហើយភ្លឺរលោង។

## ចរន្តខ្យល់

**កាន់តែមានសុខភាពល្អ នៅពេលអ្នកទទួលបានខ្យល់ត្រជាក់ស្រស់ស្រាយ**

- ផ្តល់នូវខ្យល់ស្រស់ថ្លានៅក្នុងបន្ទប់គេងដែលជាកន្លែងអ្នកចំណាយពេលសម្រាកច្រើនបំផុត



**គេងលក់ស្រួលស្កប់ស្កល់**

- Radiant Cooling បញ្ចេញនូវខ្យល់ត្រជាក់ពេញផ្ទៃបន្ទប់ជាមួយសីតុណ្ហភាពថេរ ដែលមិនធ្វើឲ្យត្រជាក់ខ្លាំង ដើម្បីធ្វើឲ្យគ្រួសារអ្នកគេងលក់ស្រួល។

## ប្រសិទ្ធភាពខ្យល់ស្រស់ថ្លា


**គេងលក់ស្រួលក្នុងកម្រិតសីតុណ្ហភាពថេរ**

- បច្ចេកវិទ្យា Inverter កាត់បន្ថយបំរែបំរួលសីតុណ្ហភាព ដើម្បីធានាបាននូវខ្យល់ត្រជាក់ស្រស់ស្រាយពេញផ្ទៃបន្ទប់


**ម៉ាស៊ីនដំណើរការស្ងាត់ល្អ ដែលមិនរំខានការគេងរបស់អ្នក**

- បច្ចេកវិទ្យា Inverter គ្រប់គ្រងដំណើរការស្ងាត់ល្អ និងគ្រប់គ្រងសីតុណ្ហភាពមិនឲ្យប្រែប្រួល។

# ផ្ដោតអារម្មណ៍បានល្អ ដើម្បីទទួលបាន លទ្ធផលសិក្សាកាន់តែប្រសើរ

## ការដំឡើងម៉ាស៊ីនត្រជាក់

**បន្ទប់សិក្សា**

1.0HP PREMIUM INVERTER R32 Single Split Type



AERO Series (U Model)



1.5HP STANDARD INVERTER R32 Single Split Type



AERO Series (PU Model)



### កង្វះខ្យល់បរិសុទ្ធបណ្ដាលឲ្យបាត់បង់អារម្មណ៍សិក្សា

- បរិយាកាសបន្ទប់សិក្សាមិនមានផាសុកភាព បណ្ដាលឲ្យកូនអ្នក មិនអាចផ្ដោតអារម្មណ៍រៀន និងធ្វើកិច្ចការសាលាបានល្អ។

# ដំណោះស្រាយខ្យល់បរិសុទ្ធនៅក្នុង បន្ទប់សិក្សា

**ការបន្សុទ្ធខ្យល់ស្រស់ថ្លា**




### សម្អាតបន្ទប់សិក្សាដោយបឺតយកកំទេចធូលីតូចៗ

- ការពារធ្នើដាក់សៀវភៅមិនឲ្យមានកំទេចធូលី ដែលអាចបង្កឲ្យអាល្លែកហ្ស៊ី។


### ខ្យល់កាន់តែបរិសុទ្ធ និងស្រស់ថ្លាជាមួយការសម្អាតល្អងធូលី ( PM2.5 )

- កម្ចាត់ល្អងធូលីតូចៗទំហំប្រហែល PM2.5 នៅក្នុងខ្យល់ ដើម្បីផ្ដល់នូវខ្យល់បរិសុទ្ធស្រស់ថ្លា។

*បំពាក់នៅលើម៉ូដែល PREMIUM INVERTER R32 ។

**ចរន្តខ្យល់**

### បរិយាកាសពេញដោយផាសុកភាពជួយដល់ការសិក្សាកូនរបស់អ្នក

- ខ្យល់ត្រជាក់សព្វពេញផ្ទៃបន្ទប់ ជាមួយការបង្ការភាពត្រជាក់ជ្រុល ដើម្បីឲ្យការផ្ដោតអារម្មណ៍រៀនសូត្រកាន់តែប្រសើរ។


### DRY MODE ថែរក្សាសៀវភៅទុកបានល្អ

- ចុចប៊ូតុង DRY MODE ដើម្បីគ្រប់គ្រងសំណើម។

**ប្រសិទ្ធភាពខ្យល់ស្រស់ថ្លា**


### ធ្វើឲ្យបន្ទប់សិក្សាមានផាសុកភាព ជាមួយការសន្សំសំចៃភ្លើងច្រើន

- Eco Mode ជាមួយ A.I សម្របតាមបរិយាកាសរបស់អ្នក ដោយផ្អែកលើលក្ខខណ្ឌកម្ដៅក្នុងបន្ទប់ និងកម្លាំងម៉ាស៊ីនត្រជាក់ ដើម្បីការសន្សំសំចៃភ្លើងបានច្រើនបំផុត។




### ពុំមានការរំខាន នាំឲ្យផ្ដោតអារម្មណ៍បានល្អ

- Quiet Mode រក្សាបាននូវសំឡេងរំខានតិចតួចបំផុត ដើម្បីធ្វើឲ្យបន្ទប់ត្រជាក់ស្រស់ស្រាយ និងមានអារម្មណ៍រៀនបានល្អ។

nanoe™ TECHNOLOGY

# ទទួលបានខ្យល់បរិសុទ្ធស្រស់ថ្លា 24 ម៉ោង
## ទោះបីម៉ាស៊ីនត្រជាក់ ON/OFF

ម៉ាស៊ីនត្រជាក់ Panasonic ថ្មី ដែលមានបំពាក់មុខងារ nanoe™ គឺជាមុខងារបន្សុទ្ធខ្យល់ឯករាជ្យមួយ ដែលអាចសម្លាប់មេរោគ និងបាក់តេរីផ្សេងៗនៅក្នុងខ្យល់កខ្វក់ ក៏ដូចជានៅជាប់សាច់ក្រណាត់ផ្សេងៗ។

ភាគល្អិតទឹកដែលស្ថិតនៅក្នុង nanoe™ អាចកម្ចាត់ក្លិនមិនល្អយ៉ាងមានប្រសិទ្ធភាព និងទប់ស្កាត់អង្គធាតុអាក្រក់ដែលប៉ះពាល់ដល់សុខភាព ដូចជាពពួកបាក់តេរី មេរោគ ផ្សិតផ្សរ អាល្លែកហ្ស៊ី លម្អងផ្កា ល្អងធូលីតូចៗជាដើម។ ភាគល្អិត nanoe™ X ថែមទាំងជួយឲ្យស្បែក និងសក់របស់អ្នកមានសំណើមផងដែរ។

Nanoe-G ដែលមានអ៊ីយ៉ុងអវិជ្ជមាន អាចកម្ចាត់ល្អងធូលីដែលមានទំហំតូចជាង PM2.5 យ៉ាងមានប្រសិទ្ធភាព។

ដូច្នេះហើយធានាបានថា មនុស្សជាទីស្រឡាញ់របស់អ្នករស់នៅប្រកបដោយផាសុកភាពនៅក្នុងផ្ទះដែលមានខ្យល់បរិសុទ្ធស្រស់ថ្លាគ្រប់ពេលវេលា។


| កម្ចាត់ក្លិនមិនល្អ | ទប់ស្កាត់សារធាតុមិនល្អ 5ប្រភេទ | | | | | ផ្តល់សំណើម | កម្ចាត់ល្អងធូលីតូចៗ( PM2.5 ) |
|---|---|---|---|---|---|---|---|
| ក្លិនស្អុយ | បាក់តេរី និងមេរោគ | ផ្សិតផ្សរ | សារធាតុ បង្កអាល្លែកហ្ស៊ី | លម្អងផ្កា | សារធាតុ បង្កឲ្យគ្រោះថ្នាក់ | ស្បែក និងសរសៃសក់ | ល្អងធូលីតូចៗ( PM2.5 ) |

nanoe™X — កម្ចាត់ក្លិនមិនល្អ និងការបំពុលនៃមេរោគដែលមាននៅក្នុងខ្យល់ និងជាប់នឹងកន្លែងផ្សេងៗដូចជាសាច់ក្រណាត់ជាដើម។

nanoe-G

## តើអ្វីគឺជា nanoe™ ?

nano-technology + electric = nanoe

nanoe™ គឺជាអេឡិចត្រូម៉ាញ៉េទិក nano-sized អាចស្វ័យប្រតិកម្មជាម៉ូលេគុលទឹកដែលសម្បូរទៅដោយរ៉ាឌីកាល់ OH ។

### ម៉ូលេគុលនេះនៅក្នុងទឹក មានប្រសិទ្ធភាពយូរអង្វែង

nanoe™ X មានប្រសិទ្ធភាពយូរអង្វែងនៅពេលវានៅក្នុងទឹក។

### នៅក្នុងបន្ទប់ដែលមានបរិមាណរ៉ាឌីកាល់ OH ច្រើន

ឧបករណ៍ដំណើរការ nanoe™ X អាចផលិតរ៉ាឌីកាល់ OH ដល់ទៅ 4.8 ទ្រីលាន ក្នុងមួយវិនាទីដែលបញ្ចេញបានធំទូលាយទៅគ្រប់កន្លុកកន្លៀតក្នុងបរិយាកាសនៅផ្ទះរបស់អ្នក។

### ម៉ូលេគុល nano ដែលមានទំហំតូចអាចជ្រាបចូលក្នុងសាច់ក្រណាត់យ៉ាងងាយស្រួល

ម៉ូលេគុល nanoe™ X មានទំហំតូចជាងម៉ូលេគុលចំហាយទឹកទៅទៀត គឺមានទំហំ 5-20nm ដែលអាចជ្រាបចូលយ៉ាងងាយទៅក្នុងសាច់ក្រណាត់ ដើម្បីទប់ស្កាត់ការកកើតសារធាតុពុល និងក្លិនមិនល្អបានយ៉ាងមានប្រសិទ្ធភាព។




# កម្ចាត់ក្លិនមិនល្អ nanoeX

## ពេលវេលាដ៏រីករាយ រស់នៅក្នុងបរិយាកាសពោរពេញ ដោយផាសុកភាព

### ប្រភេទក្លិនមិនល្អ ដែលធ្វើឲ្យការរស់នៅរបស់អ្នកមិនមានផាសុកភាព





## តើ nanoeX ដំណើរការយ៉ាងដូចម្ដេច?




ឧបករណ៍ nanoe™ X ស៊េរីចុងក្រោយ បានប្រើប្រព័ន្ធ “multi-leader discharge” ដែលអាចបញ្ចេញរ៉ាឌីកាល់ OH ច្រើនជាង 10ដង តាមរយៈអេឡិចត្រូតមានមុខស្រួចចំនួន 4 ដើម្បីកម្ចាត់សារធាតុមិនល្អកាន់តែមានប្រសិទ្ធភាពខ្ពស់។




nanoe™ X ចាប់យកក្លិនមិនល្អចេញពីសាច់ក្រណាត់។

រ៉ាឌីកាល់ OH ធ្វើប្រតិកម្មផ្ដាច់ក្លិនមិនល្អចេញពីសាច់ក្រណាត់។

កម្ចាត់ក្លិនមិនល្អចេញសាច់ក្រណាត់។



**ភាគល្អិតនៃចំហាយទឹក**

ភាគល្អិតនៃចំហាយទឹកមានទំហំធំ ដូច្នេះវាមិនអាចជ្រាបចូលជ្រៅទៅក្នុងសរសៃសាច់ក្រណាត់បានទេ។

nanoeX

មានប្រសិទ្ធភាពជ្រាបចូលយ៉ាងជ្រៅទៅក្នុងសរសៃសាច់ក្រណាត់។

ទំហំ៖ ប្រហែល 5-20 ណាណូម៉ែត្រ

ហ៊ុមព័ទ្ធនិងទប់ស្កាត់ការបំពុល (ពពួកបាក់តេរី និងមេរោគ ពពួកផ្សិត អាល្លែកហ្ស៊ី លម្អងផ្កា និងសារធាតុដែលបង្កគ្រោះថ្នាក់)។




nanoe™ X ចាប់យកបាក់តេរី។

រ៉ាឌីកាល់ OH ទាញយកអ៊ីដ្រូសែនពីបាក់តេរី។

រ៉ាឌីកាល់ OH បំលែងអ៊ីដ្រូសែននៅក្នុងបាក់តេរី ទៅជាទឹក និងទប់ស្កាត់សកម្មភាពបាក់តេរី។

## កាត់បន្ថយក្លិនមិនល្អ ដែលជួបប្រទះញឹកញាប់

nanoe™ X មានសមត្ថភាពជួយកម្ចាត់ក្លិនមិនល្អ ដែលជាប់នៅក្នុងសាច់ក្រណាត់ ហើយធ្វើឲ្យផ្ទះរបស់អ្នកមានបរិយាកាសស្រស់ស្រាយពោរពេញដោយផាសុកភាព។

# កម្ចាត់សារធាតុមិនល្អទាំង 5 ប្រភេទ nanoeX

## កម្ចាត់សារធាតុពុល និងជួយការពារមនុស្សជាទីស្រឡាញ់របស់អ្នក

### សារធាតុមិនល្អ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អ្នក








## កម្ចាត់ខ្យល់កខ្វក់ និងទប់ស្កាត់ការបំពុលនៃសារធាតុមិនល្អ

nanoe™ X បានទប់ស្កាត់សារធាតុដែលគ្រោះថ្នាក់ខ្លាំងក្នុងខ្យល់ ធ្វើឲ្យមនុស្សជាទីស្រឡាញ់របស់អ្នកចៀសឆ្ងាយពីពពួកមេរោគ និងអាល្លែកហ្ស៊ីផ្សេងៗ។

# សំណើម

nanoe X

## ផ្តល់សំណើមដល់ស្បែក និងសក់ និងផ្តល់នូវភាពស្រស់ស្រាយបានគ្រប់ពេល

### សំណើមមិនគ្រប់គ្រាន់ សម្រាប់ស្បែក និងសក់




### តើ nanoe™ X ដំណើរការយ៉ាងដូចម្តេច?

#### រក្សាសំណើមដល់ស្បែក




[ដំបូង] nanoe™ X រួមបញ្ចូលគ្នាជាមួយសារធាតុខ្លាញ់ធម្មជាតិ ដើម្បីលាបពីលើស្បែក។

[28 ថ្ងៃក្រោយ] ស្បែកចាប់ផ្តើមរលោង និងមានសំណើមល្អ។

#### ថែរក្សាសរសៃសក់មានទម្ងន់ និងភ្លឺរលោង


វាជួយឲ្យសរសៃសក់មានសំណើម មានទម្ងន់ ទន់និងភ្លឺរលោង ថែមទាំងងាយស្រួលសិតទៀតផង។

## សំណើមជួយថែរក្សាបាន ទាំងស្បែក និងសរសៃសក់

ភាគល្អិតៗនៃទឹកដែលជួយថែទាំសរសៃសក់ និងស្បែកឲ្យទន់ និងភ្លឺរលោងស្រស់ស្អាត។

# កម្ចាត់ល្អងធូលីតូចៗ (PM2.5)

nanoe-G

## ការបន្សុទ្ធខ្យល់ ដើម្បីខ្យល់ដង្ហើមស្រស់ថ្លា

### តើ nanoe-G ដំណើរការយ៉ាងដូចម្តេច?



ឧបករណ៍អ៊ីយ៉ុង nanoe-G ចាប់ផ្តើមដំណើរការបញ្ចេញអ៊ីយ៉ុងអវិជ្ជមាន

អ៊ីយ៉ុងអវិជ្ជមានចាប់យកល្អងធូលី

ល្អងធូលី ត្រូវបានតោងជាប់នឹងតម្រងសំណាញ់ខ្យល់

### ល្អងធូលីដីតូចៗ (PM 2.5) អាចបង្កឲ្យមានជំងឺ

## កម្ចាត់ល្អងធូលីតូចៗ ដែលមានទំហំ PM2.5

អ៊ីយ៉ុងអវិជ្ជមានត្រូវបានបញ្ចេញ ដើម្បីទៅចាប់យកល្អងធូលីតូចៗ (ទំហំ PM2.5) ហើយភាគល្អិតមិនល្អនោះ ក៏ត្រូវបាននាំយកត្រឡប់ទៅជាប់នឹងតម្រងសំណាញ់របស់ម៉ាស៊ីនត្រជាក់បានយ៉ាងល្អ។

# ការបន្សុទ្ធខ្យល់ឲ្យបរិសុទ្ធ និងកម្ចាត់សារធាតុកខ្វក់ពេញមួយថ្ងៃ

## ការបន្សុទ្ធខ្យល់
ខណៈ
ម៉ាស៊ីនមិនបញ្ចេញភាពត្រជាក់ ដែលជួយសន្សំសំចៃថាមពលបានច្រើន។

### ត្រឹមតែ 25W/ ម៉ោង *

ការប្រើប្រាស់ថាមពលអស់តិចជាមួយដុំកង្ហារស៊ីថាមពលត្រឹម 25W/ម៉ោង សម្រាប់ប្រភេទម៉ាស៊ីនមួយ។

បន្សុទ្ធខ្យល់
ពេញ
គេហដ្ឋាន
24 ម៉ោង

### មិនបាច់ចំណាយលើការថែទាំ

មិនត្រូវការចំណាយលើការថែទាំ ចំពោះឧបករណ៍ nanoe™ X ឡើយ។

**រក្សាទុក nanoe™ នៅប៊ូតុង ON ដើម្បីបំបាត់ក្លិនមិនល្អ កម្ចាត់បាក់តេរី និងមេរោគ រួមទាំងសម្អាតល្អងធូលី(PM2.5)**

មុនចេញពីផ្ទះ សូមចុចបើក ( ON ) ដំណើរការមុខងារ nanoe™ ដើម្បីបំបាត់ក្លិនមិនល្អ កម្ចាត់ បាក់តេរី និងមេរោគ រួមទាំងសម្អាតល្អងធូលី ( PM2.5 )។



**បរិយាកាសស្រស់ស្រាយនិងមានផាសុកភាពសម្រាប់មនុស្សជាទីស្រឡាញ់**

ការយកចិត្តទុកដាក់លើគុណភាពខ្យល់បរិសុទ្ធនៅក្នុងគេហដ្ឋានធ្វើឲ្យអ្នករីករាយគ្រប់ពេលនៅជាមួយគ្រួសារ ហើយអ្នកក៏អាចគេងសម្រាកនៅក្នុងបន្ទប់ទទួលភ្ញៀវប្រកបដោយផាសុកភាព។

## ការបន្សុទ្ធខ្យល់ពេលអ្នកមិននៅផ្ទះ

## ការបន្សុទ្ធខ្យល់ពេលអ្នកនៅក្នុងផ្ទះ

**ជំហានទី 1៖**
**ចុចបិទ (OFF) ម៉ាស៊ីនត្រជាក់**

**ជំហានទី 2៖**
**ចុចបើក ( ON ) លើមុខងារ nanoe™**




* ការប្រើប្រាស់ថាមពលអាចខុសគ្នាទៅតាមម៉ូដែល .






# ប្រព័ន្ធបន្សុទ្ធខ្យល់ឲ្យបរិសុទ្ធស្រស់ថ្លា ដ៏ពិសេសមុនគេបង្អស់របស់ Panasonic

បច្ចេកវិទ្យា nanoe™ របស់ក្រុមហ៊ុន Panasonic គឺជាប្រព័ន្ធបន្សុទ្ធខ្យល់ឲ្យបរិសុទ្ធស្រស់ថ្លា ដែលថែទាំបរិយាកាសរស់នៅរបស់អ្នកជាមួយគ្រួសារ ពោរពេញដោយផាសុកភាព និងសេចក្ដីសុខ។

## ប្រសិទ្ធភាពនៃបច្ចេកវិទ្យា nanoe™ ត្រូវបានទទួលស្គាល់ដោយអ្នកឯកទេសក្នុងវិស័យនីមួយៗ

### ត្រូវបានណែនាំឲ្យប្រើប្រាស់នៅទីតាំងនានាដូចជាស្ថាប័នវេជ្ជសាស្ត្រ ឬកន្លែងផ្សេងទៀត ដែលទាមទារឲ្យអនាម័យខ្ពស់។

**Professor**
**Masafumi Mukamoto**
Osaka Prefecture University
Veterinary Infectious Disease Studies

ប្រភេទផ្សិតផ្ទរជាច្រើនតែងតែចូលក្នុងផ្ទះតាមមនុស្សនិងខ្យល់ ទោះបីជាយើងបានការពារដោយវិធីផ្សេងៗ តាមរបៀបរស់នៅប្រចាំថ្ងៃរបស់យើងក៏ដោយ។ វាពិបាកណាស់ ក្នុងរារាំងការលូតលាស់របស់ផ្សិត ជាពិសេស នៅក្នុងបរិស្ថានសើម។ ប៉ុន្តែជាមួយនឹង nanoe™ X យើងមានលទ្ធផលពិសោធន៍ * ដែលបង្ហាញថាយើងអាចទប់ស្កាត់កំណើននៃប្រភេទផ្សិតដែលបានប្រទះឃើញនៅទីកន្លែងផ្សេងៗនៅក្នុងផ្ទះបាន។ ក្នុងនាមជា nanoe™ X វាមានសមត្ថភាពទប់ស្កាត់ បាក់តេរីនិងមេរោគដែលមើលមិនឃើញនៅក្នុងបរិយាកាសរស់នៅរបស់យើង ហើយវានឹងផ្ដល់នូវបរិស្ថានស្អាត។ ខ្ញុំសូមផ្ដល់អនុសាសន៍ថា ឧបករណ៍ដែលមានបច្ចេកវិទ្យា nanoe™ X គួរតែបំពាក់នៅក្នុងអគារដែលតម្រូវឲ្យមានអនាម័យ ដូចជានៅ សាលារៀនកន្លែងថែទាំកុមារ និងស្ថាប័នវេជ្ជសាស្ត្រជាដើម។

### សង្ឃឹមថានឹងបង្កើតកន្លែងដែលមានផាសុកភាពឲ្យកាន់តែច្រើនបន្ថែមទៀតសម្រាប់អ្នកដែលមានបញ្ហាជំងឺហឺត ឬអាឡែកហ្ស៊ីស្បែក។



**Professor**
**Masahiro Sakaguchi**
Azabu University School of Veterinary
Medicine Department of Veterinary Medicine

លទ្ធផលពិសោធន៍របស់យើងបង្ហាញថា nanoe™ X មានលទ្ធភាពទប់ស្កាត់អាឡែកហ្ស៊ី ដែលអាចបណ្ដាលឲ្យ កើតជំងឺហឺត ឬកន្ទួលរមាស់។ អ្នកជំងឺហឺតនៅពេលបច្ចុប្បន្ននេះ មានការកើនឡើង (យោងតាមទិន្នន័យអង្គការសុខភាពពិភពលោក * ) ហើយវាសំខាន់ណាស់ ដើម្បីចាត់វិធានការណ៍បង្ការអាឡែកហ្ស៊ី ដែលយើងស្រូបចូលតាមខ្យល់ដង្ហើម ចូលទៅក្នុងរាងកាយដោយមិនដឹងខ្លួន នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ក្នុងនាមជា nanoe™ X វាបានជួយទប់ស្កាត់សារធាតុបង្កអាឡែកហ្ស៊ីយ៉ាងមានប្រសិទ្ធភាព ដែលយើងមើលមិនឃើញ។ យើងរំពឹងទុកថាវានឹងបង្កើត នូវបរិយាកាសស្រស់ស្រាយប្រកបដោយផាសុកភាពសម្រាប់មនុស្សដែលរងផលប៉ះពាល់ពីជំងឺហឺត និងកន្ទួលរមាស់។ នៅពេលដែល nanoe™ X ត្រូវបានបញ្ជាក់ថាមានសុវត្ថិភាព នោះមានន័យថា nanoe™ X ប្រាកដជាអាចផ្ដល់នូវបរិយាកាសរស់នៅស្រស់ស្រាយ និងសប្បាយរីករាយដល់គ្រួសារនិងកូនតូចៗជាទីស្រឡាញ់របស់អ្នក។

*1 លទ្ធផលពិសោធន៍បានបង្ហាញថា nanoe™ មានប្រសិទ្ធភាពខ្ពស់ ក្នុងការទប់ស្កាត់ការលូតលាស់នៃប្រភេទផ្សិតជាច្រើនប្រភេទ ដែលយើងបានរកឃើញញឹកញាប់នៅក្នុងផ្ទះដូចជាពពួកផ្សិត៖ Cladosporium, Aspergillus, Penicillium, Alternaria, Fusarium, Eurotium, Mucor និង Stachybotrys។

*2 ព័ត៌មានអំពីជំងឺហឺតទងសួតរបស់អង្គការសុខភាពពិភពលោក៖ http://www.who.int/mediacentre/factsheets/fs206/en/

** ការចង្អុលបង្ហាញ និងសេចក្តីថ្លែងការណ៍ខាងលើត្រូវបានធ្វើឡើងយោងទៅតាមព័ត៌មានដូចដែលមាន។



## ហេតុអ្វីត្រូវប្រើបច្ចេកវិទ្យា nanoe™




### បន្សុទ្ធខ្យល់បរិសុទ្ធស្រស់ថ្លាពេញមួយថ្ងៃ

- បច្ចេកវិទ្យា nanoe™ អាចដំណើរការដោយឯករាជ្យ ដើម្បីបន្តការសម្អាត និងកម្ចាត់ក្លិនមិនល្អនៅបន្ទប់ទទួលភ្ញៀវរបស់អ្នក។


### ជំងឺហឺត និងប្រតិកម្មអាឡែកហ្ស៊ី

- nanoe™ X ត្រូវបានអនុម័តដោយ Sensitive Choice ដែលជួយដល់អ្នកប្រើប្រាស់ទូទាំងពិភពលោកឲ្យរស់នៅបានប្រសើរចាកឆ្ងាយពីជំងឺហឺត និងអាឡែកហ្ស៊ី។




### ម៉ូលេគុល $H_2O$ ធម្មជាតិ

- nanoe™ X ត្រូវបានបង្កើតឡើងចេញពីសំណើមនៅក្នុងខ្យល់ដែលមានសមាសធាតុសកម្មខ្ពស់ដែលគេស្គាល់ថាជារ៉ាឌីកាល់ hydroxyl (OH)។



អាចរស់នៅក្នុងខ្យល់លើសពី 600 វិនាទី

### ម៉ូលេគុល nanoe™ X មានអាយុកាលវែង

- មានអាយុកាលវែងជាងរ៉ាឌីកាល់ OH រហូត 6 ដង * ដើម្បីធ្វើការបានកាន់តែទូលាយគ្រប់ទីកន្លែង។

*អាយុកាលនអ៊ីយ៉ុងក្នុងខ្យល់ទូទៅ (អ៊ីយ៉ុងអវិជ្ជមាន) គឺចាប់ពី 10 វិនាទីដល់ 100 វិនាទី។

### មានប្រសិទ្ធភាពលើសាច់ក្រណាត់ និងកម្រាលផ្សេងៗ

- ភាគល្អិត nanoe™ X បានចូលទៅបំបាត់ក្លិន និងទប់ស្កាត់ការបំពុលលើផ្ទៃក្រណាត់ ក៏ដូចជាជ្រាបចូលយ៉ាងជ្រៅទៅក្នុងសាច់ក្រណាត់។




### មិនបាច់ចំណាយលើការថែទាំ

- ឧបករណ៍ nanoe™ X មិនតម្រូវឲ្យមានការថែទាំអ្វីទាំងអស់ nanoe™ X បង្កើតអ៊ីយ៉ុងទឹកដែលមានក្នុងខ្យល់តែប៉ុណ្ណោះ។



### បរិយាកាសស្រស់ថ្លា និងមិនមានសារធាតុគីមី

- សុវត្ថិភាពនៃ nanoe™ X និង nanoe™ ត្រូវបានធ្វើការសាកល្បង និងបង្ហាញឲ្យឃើញដោយវិទ្យាស្ថាន និងមន្ទីរពិសោធន៍។ ចូលទៅមើលនៅគេហទំព័ររបស់យើង ដើម្បីពិនិត្យមើលបញ្ជីឈ្មោះនៃទិន្នន័យធ្វើតេស្តស្ដីពីសុវត្ថិភាព។

https://www.panasonic.com/global/corporate/technology-design/technology/nanoe.html

# ចរន្តខ្យល់



## សុខភាពល្អ ត្រជាក់ស្រស់ស្រាយ ជាមួយ ចរន្តខ្យល់បាញ់ចេញលឿន និងឆ្ងាយល្អ

ដំណោះស្រាយខ្យល់ស្រស់ថ្លារបស់ Panasonic ផ្តល់នូវខ្យល់ត្រជាក់ ប្រកបដោយផាសុកភាព ដែលអាចបំពេញតាមតម្រូវការរបស់អ្នក និងគ្រួសារ ដើម្បីទទួលបាននូវជម្រើសដ៏ល្អប្រសើរសម្រាប់សុខភាព។

## ថ្មី ប៊ូតុង POWERFUL សម្រាប់បំពេញតម្រូវការអ្នកចង់ត្រជាក់ភ្លាម។

### ទទួលបានខ្យល់ត្រជាក់ស្រស់ស្រាយកាន់តែលឿន ដោយគ្រាន់តែចុចប៊ូតុងមួយប៉ុណ្ណោះ

- ប៊ូតុង POWERFUL នឹងបញ្ជាទៅ compressor និងកង្ហារខាងក្នុងឲ្យដំណើរការល្បឿនលឿន ដូចនេះអ្នកអាចទទួលបានខ្យល់ត្រជាក់ខ្លាំងភ្លាមៗ។




ចុច POWERFUL/ ECO តែម្តងដើម្បីបើកដំណើរការប៊ូតុង POWERFUL

### នៅពេលដែលចាប់ផ្តើមដំណើរការខ្យល់ត្រជាក់ក្នុងកម្រិត POWERFUL

- ប៊ូតុង POWERFUL ធ្វើឲ្យបន្ទប់របស់អ្នកត្រជាក់កាន់តែលឿនប្រមាណ18% * នៅពេលអ្នកចុចបើកដំណើរការម៉ាស៊ីនត្រជាក់របស់អ្នក។
- សោយសុខជាមួយខ្យល់ត្រជាក់ស្រស់ស្រាយភ្លាមៗ ទោះបីជាសីតុណ្ហភាពថ្ងៃនេះក្តៅខ្លាំងក៏ដោយ។


*ការប្រៀបធៀបប៊ូតុង Powerful Cool Mode និងប៊ូតុងត្រជាក់ធម្មតា ដោយការប្រើប្រាស់ម៉ូដែល Inverter 1.5HP

| POWERFUL Cool Mode: | | Normal Cool Mode: | |
|---|---|---|---|
| POWERFUL Mode, Outside temperature | : 35°C/24°C | Cool Mode, Outside temperature | : 35°C/24°C |
| Remote setting temperature | : 25°C, with Fan Speed: Powerful. | Remote setting temperature | : 25°C, with Fan Speed: High. |
| Horizontal Airflow direction | : Middle | Horizontal Airflow direction | : Middle |
| Vertical Airflow direction | : Straight | Vertical Airflow direction | : Straight |

Total time needed to cool down the room from 35°C to 29°C is measured.
At Panasonic Amenity Room (size : 16.6m²)
The effect differs according to conditions in installation and usage.

*ប្រើប្រាស់បានសម្រាប់តែ STANDARD INVERTER និង STANDARD NON-INVERTER R32 ប៉ុណ្ណោះ។





## SKYWING

### គ្របដណ្តប់ដោយខ្យល់ត្រជាក់ធំទូលាយ

ធានាថាត្រជាក់គ្រប់ជ្រុងនៅក្នុងបន្ទប់។








- សន្ទះបក់ខ្យល់ធំជាងមុន ដែលជួយបក់ខ្យល់ឲ្យត្រជាក់លឿនពេញផ្ទៃបន្ទប់។

### Radiant Cooling

- ចរន្តខ្យល់ត្រជាក់បាញ់ស្រោចស្រពពីលើពិតាន និងជញ្ជាំង សម្រាប់បំពេញតម្រូវការត្រជាក់សព្វកន្លែង។

#### ការសិក្សាពីចរន្តខ្យល់ Radiant Cooling




| ការសាកល្បងដោយការបាញ់ផ្សែង | ការសាកល្បងវាស់ស្ទង់សីតុណ្ហភាព | បឺតខ្យល់ចូលតាមបាតម៉ាស៊ីន |
|---|---|---|
| SKYWING បាញ់ខ្យល់នៅខាងលើដើម្បីភាពត្រជាក់ពិតាន និងជញ្ជាំង។ | បឺតយកកម្តៅចេញពីពិតាន និងជញ្ជាំងយ៉ាងមានប្រសិទ្ធភាព ដោយបាញ់ខ្យល់ត្រជាក់ពេញផ្ទៃបន្ទប់។ | បឺតយកខ្យល់ក្តៅតាមបាតម៉ាស៊ីន ហើយបញ្ចេញខ្យល់ត្រជាក់នៅផ្នែកខាងលើ។ |

### Fast Cooling

- ត្រជាក់លឿនជាមួយបច្ចេកវិទ្យា Inverter Compressor P-TECh ។

#### ការសិក្សាពីចរន្តខ្យល់ Fast Cooling



| ការសាកល្បងដោយការបាញ់ផ្សែង | ការសាកល្បងវាស់ស្ទង់សីតុណ្ហភាព | |
|---|---|---|
| | បាញ់ខ្យល់ត្រជាក់ធម្មតា | បាញ់ខ្យល់ត្រជាក់លឿន |
| SKYWING ចរន្តខ្យល់បាញ់តម្រង់ចុះមកក្រោមចំអ្នក សម្រាប់ការដែលអ្នកចង់ត្រជាក់ភ្លាមៗ។ | ត្រជាក់យឺត ដែលមិនទទួលបានភាពត្រជាក់ពេញផ្ទៃបន្ទប់។ | ចរន្តខ្យល់ត្រជាក់បាញ់ខ្លាំង ធ្វើឲ្យបន្ទប់ត្រជាក់សព្វកន្លែង។ |

## AEROWINGS

### ចរន្តខ្យល់ខ្លាំងនិងបាញ់បានឆ្ងាយ

ចរន្តខ្យល់បាញ់បានឆ្ងាយ ហើយលឿនជាងធម្មតា ដែលធ្វើឲ្យត្រជាក់ពេញផ្ទៃបន្ទប់។



### Shower Cooling

- ចរន្តខ្យល់ដែលមានសំណើមបាញ់ខ្យល់ត្រជាក់លឿន និងចរន្តខ្យល់ខ្លាំងអាចសាយភាយពេញផ្ទៃបន្ទប់ ដែលហ៊ុមព័ទ្ធដោយភាពត្រជាក់ស្មើសព្វកន្លែង។

#### ការសិក្សាពីចរន្តខ្យល់ដែលមានសំណើម Shower Cooling



| ការសាកល្បងដោយការបាញ់ផ្សែង | ការសាកល្បងវាស់ស្ទង់សីតុណ្ហភាព | បឺតយកខ្យល់ក្តៅតាមផ្នែកខាងលើ |
|---|---|---|
| AEROWINGS បាញ់ខ្យល់ទៅខាងលើ និងសាយភាយបានធំទូលាយ ដែលធ្វើឲ្យត្រជាក់ពេញផ្ទៃបន្ទប់។ | AEROWINGS បាញ់ខ្យល់ត្រជាក់បានឆ្ងាយ &តម្រង់ឆ្ពោះទៅពិតាន ដោយចៀសវាងតម្រង់ចំមនុស្សអាចធ្វើឲ្យត្រជាក់មិនស្រួលខ្លួន។ | បឺតយកខ្យល់ក្តៅនៅផ្នែកខាងលើ និងបាញ់ខ្យល់ត្រជាក់ចេញមកវិញតាមផ្នែកខាងក្រោម ដើម្បីផ្លាស់ប្តូរខ្យល់សាយភាយពេញផ្ទៃបន្ទប់។ |

### ចរន្តខ្យល់ខ្លាំង បាញ់បានឆ្ងាយ និងរហ័ស


1. **ម៉ូទ័រស្វ័យប្រវត្តិ 2**
   គ្រប់គ្រងដំណើរការរបស់ផ្លិតខ្យល់ខាងក្រៅ និងផ្លិតខ្យល់ខាងក្នុងដាច់ដោយឡែកពីគ្នា។
2. **ផ្លិតខ្យល់ខាងក្នុង**
   Compresses and concentrates cool air.
3. **ផ្លិតខ្យល់ខាងក្រៅមានទំហំធំ**
   ជួយដល់ចរន្តបាញ់ខ្យល់បានកាន់តែឆ្ងាយ។

- ចរន្តខ្យល់ខ្លាំងបាញ់បានឆ្ងាយ និងរហ័ស រួមជាមួយផ្លិតខ្យល់ចំនួន2 ដែលដំណើរការដោយម៉ូទ័រស្វ័យប្រវត្តិ។



### Fast Cooling

- AEROWING មានផ្លិតខ្យល់ភ្លោះដែលជួយដល់ចរន្តខ្យល់បាញ់ចេញមកខ្លាំង ហើយបាញ់បានឆ្ងាយ ដែលអាចតម្រង់ចុះមកចំអ្នក ធ្វើឲ្យអ្នកត្រជាក់ភ្លាមៗ។

#### ការសិក្សាពីចរន្តខ្យល់ Fast Cooling



| ការសាកល្បងដោយការបាញ់ផ្សែង | ការសាកល្បងវាស់ស្ទង់សីតុណ្ហភាព | |
|---|---|---|
| | បាញ់ខ្យល់ត្រជាក់ធម្មតា | បាញ់ខ្យល់ត្រជាក់លឿន |
| AEROWINGS ចរន្តខ្យល់បាញ់តម្រង់ចុះមកក្រោមចំអ្នក សម្រាប់ការដែលអ្នកចង់ត្រជាក់ភ្លាមៗ។ | ត្រជាក់យឺត ដែលធ្វើឲ្យមិនត្រជាក់ពេញផ្ទៃបន្ទប់។ | ចរន្តខ្យល់បាញ់ខ្លាំង ត្រជាក់ភ្លាមៗ ដែលធ្វើឲ្យបន្ទប់ត្រជាក់សព្វកន្លែង។ |

## BIG FLAP

### ចរន្តខ្យល់បាញ់ឆ្ងាយ

ផ្លិតខ្យល់នៅខាងក្រោមធំ បាញ់ខ្យល់ត្រជាក់ពេញផ្ទៃបន្ទប់។



### Shower Cooling

- ខ្យល់ត្រជាក់បាញ់ឡើងលើក្នុងទម្រង់ស្រោចស្រពនូវភាពត្រជាក់ស្មើសព្វកន្លែងពេញផ្ទៃបន្ទប់។



### Fast Cooling

- ផ្លិតខ្យល់ធំ បញ្ចេញនូវខ្យល់ខ្លាំងតម្រង់ចុះក្រោមចំអ្នក សម្រាប់ការបំពេញតម្រូវការត្រជាក់លឿនភ្លាមៗ។

# ប្រសិទ្ធភាពខ្យល់បរិសុទ្ធស្រស់ថ្លា

## បច្ចេកវិទ្យាថែរក្សាបរិស្ថាន

ជម្រើសកាន់តែឆ្លាតវៃ និងកាន់តែស្រស់បំព្រង ជាមួយបច្ចេកវិទ្យាសន្សំសំចៃថាមពលសម្រាប់ការរស់នៅយូរអង្វែង។

NEW ECO+A.I. | INVERTER

ថ្មី ECO+A.I.

## ផ្តល់នូវភាពត្រជាក់ប្រកបដោយផាសុកភាព និងការសន្សំសំចៃភ្លើង ប្រកបដោយភាពឆ្លាតវៃ




ម៉ាស៊ីនត្រជាក់ **Panasonic** ម៉ូដែលថ្មីដែលមានប៊ូតុង **ECO** រួមជាមួយនឹងការគ្រប់គ្រងការបញ្ញាលក្ខណៈឆ្លាតវៃ (A.I.) អាចដឹងពីស្ថានភាពពិតនៃបរិយាកាសបន្ទប់របស់អ្នក។ ថាមពលសន្សំសំចៃអាចដំណើរការការសន្សំសំចៃភ្លើងបានច្រើនបំផុតផ្អែកលើបរិយាកាសបន្ទប់ ដោយធ្វើការកែតម្រូវកម្រិតសីតុណ្ហភាព ECO ដោយស្វ័យប្រវត្តិ ផ្អែកលើលក្ខខណ្ឌកម្តៅ និងសមត្ថភាពរបស់ម៉ាស៊ីនត្រជាក់។

## សម្រួបតាមបរិយាកាសផ្ទះរបស់អ្នកដោយស្វ័យប្រវត្តិ និងការសន្សំសំចៃថាមពលខ្ពស់បំផុត

ដោយសារបរិយាកាសបន្ទប់នីមួយៗក្នុងផ្ទះរបស់អ្នកខុសៗគ្នាដូចនេះ ប៊ូតុង ECO ដែលមានការគ្រប់គ្រងបញ្ញាលក្ខណៈឆ្លាតវៃ A.I. នឹងផ្តល់នូវភាពត្រជាក់ក្នុងបន្ទប់របស់អ្នកយ៉ាងមានប្រសិទ្ធភាព ផ្អែកលើកម្តៅនៃបន្ទប់នីមួយៗ។ បច្ចេកវិទ្យាទំនើបនេះ បានកំណត់តុល្យភាពនៃសីតុណ្ហភាពដែលចូលរួមការថែរក្សាបរិស្ថាន ECO តាមរយៈការប្រើប្រាស់ថាមពល និងពេលវេលាកំណត់កម្រិតសីតុណ្ហភាពទៅតាមតម្រូវការរបស់អ្នក ដើម្បីធានាថាអ្នកទទួលបានភាពត្រជាក់ប្រកបដោយផាសុកភាព និងការខ្ជះខ្ជាយថាមពលតិចបំផុត។

ប៊ូតុង ECO និងការគ្រប់គ្រងបញ្ញាលក្ខណៈឆ្លាតវៃ A.I. នឹងធ្វើការសិក្សាវាយតម្លៃជាក់ស្តែងថា សីតុណ្ហភាពកម្រិតណាដែលចូលរួមថែរក្សាបរិស្ថាន ECO ដោយផ្អែកលើ៖

1. លក្ខខណ្ឌបន្ទប់
2. ប្រភពបង្កើតកម្តៅក្នុងបន្ទប់៖
   (A) ពន្លឺព្រះអាទិត្យ និងពន្លឺក្នុងបន្ទប់
   (B) កុំព្យូទ័រ និងគ្រឿងបរិក្ខារ
   (C) កម្តៅខ្លួនមនុស្ស

**វិធីប្រើប្រាស់ចុចបើកប៊ូតុង ECO និងការគ្រប់គ្រងបញ្ញាឆ្លាតវៃ A.I.**

- ចុច POWERFUL/ECO ចុចប៊ូតុង POWERFUL ដើម្បីបើក
- ចុច POWERFUL/ECO ចុចប៊ូតុង 2 ដង ដើម្បីបើកប៊ូតុង ECO
- ចុច POWERFUL/ECO ចុចប៊ូតុង 3 ដង ដើម្បី លុបចោល/បិទ ECO


### នៅពេលដែលម៉ាស៊ីនត្រជាក់របស់អ្នកបើកដំណើរការ

ការបង្ហាញទី1 - ពន្លឺព្រះអាទិត្យចាំងក្តៅខ្លាំងចូលក្នុងបន្ទប

- ត្រូវការត្រជាក់លឿន

**ការប្រើប្រាស់ប៊ូតុង ECO និង A.I. ដើម្បីទទួលបានការសន្សំសំចៃថាមពលមានប្រសិទ្ធភាព នៅពេលដែលបន្ទប់ទទួលបានភាពត្រជាក់ប្រកបដោយផាសុកភាពល្អបំផុតជាមុនសិន។**

UP TO 20%* ENERGY SAVING ECO+A.I.



ការបង្ហាញទី 2 - ត្រជាក់នាពេលរាត្រី

- មិនត្រូវការត្រជាក់លឿន

**ការប្រើប្រាស់ប៊ូតុង ECO និង A.I. ដើម្បីទទួលបានការសន្សំសំចៃថាមពលមានប្រសិទ្ធភាព ក្នុងពេលដែលបន្ទប់ទទួលបានភាពត្រជាក់ខ្លាំងជ្រុល។**

*** ការប្រៀបធៀបរវាងប៊ូតុង ECO និងប៊ូតុងធម្មតា ដោយប្រើប្រាស់ម៉ាស៊ីនត្រជាក់ប្រភេទ Inverter 1.5HP ។**

**ECO Mode:**

| | | |
|---|---|---|
| ECO Mode, Outside temperature | : | 35°C/24°C |
| Remote setting temperature | : | 25°C, with Fan Speed: High. |
| Horizontal Airflow direction | : | Middle |
| Vertical Airflow direction | : | Straight |

ការប្រើប្រាស់ថាមពលសរុប ត្រូវបានវាស់ស្ទង់ក្នុងរយៈពេលដំណើរការថេរក្រោម 1ម៉ោង ។ ការសាកល្បងក្នុងបន្ទប់នៅក្នុងក្រុមហ៊ុន Panasonic ទំហំ 13.3m² ប្រសិទ្ធភាពអាចខុសគ្នាអាស្រ័យលើលក្ខខណ្ឌដំឡើង និងការប្រើប្រាស់។

### បន្ទាប់ពីទទួលបាននូវកម្រិតសីតុណ្ហភាពត្រជាក់ដែលអ្នកបានកំណត់



- រក្សាបានភាពត្រជាក់ប្រកបដោយផាសុកភាពទាំងយប់ទាំងថ្ងៃ
- អាចសន្សំសំចៃថាមពលបាន បន្ទាប់ពីទទួលបានកម្រិតសីតុណ្ហភាពមួយដូចដែលអ្នកបានការកំណត់។

**ប៊ូតុង ECO និង A.I. នឹងបន្តដំណើរការសន្សំសំចៃថាមពល និងធ្វើការកែតម្រូវកម្រិតសីតុណ្ហភាពនៅក្នុងបន្ទប់ដោយស្វ័យប្រវត្តិ ដើម្បីរក្សាឲ្យបានភាពត្រជាក់ប្រកបដោយផាសុកភាព។**

**Normal Mode:**

| | | |
|---|---|---|
| Normal Mode, Outside temperature | : | 35°C/24°C |
| Remote setting temperature | : | 25°C, with Fan Speed: High. |
| Horizontal Airflow direction | : | Middle |
| Vertical Airflow direction | : | Straight |

* អនុវត្តលើម៉ូដែល STANDARD INVERTER R32 ប៉ុណ្ណោះ។

ECO+A.I.

INVERTER

## INVERTER

## ការគ្រប់គ្រងសីតុណ្ហភាពច្បាស់លាស់ និងការសន្សំសំចៃថាមពលខ្ពស់

ម៉ាស៊ីនត្រជាក់ Panasonic ជួយកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី តាមរយៈការផ្លាស់ប្តូរល្បឿននៃ Compressor នៅពេលដែលបំរែបំរួលសីតុណ្ហភាពក្នុងបន្ទប់ត្រជាក់ជាងការកំណត់។ ដូចនេះអ្នកអាចរក្សាបានភាពត្រជាក់ប្រកបដោយផាសុកភាព។



**ខួរក្បាលឆ្លាតវៃ "BRAIN" របស់ Inverter - The Micro Computer**

សម្រេចចិត្តត្រឹមត្រូវបំផុតក្នុងប្រតិបត្តិការកែតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី នៅពេលណាដែលបន្ទប់ទទួលបានភាពត្រជាក់ពេក។



**PAM (Pulse Amplitude Modulation)**

បង្កើនវ៉ុល Compressor យ៉ាងរហ័ស ដើម្បីផ្តល់នូវភាពត្រជាក់ខ្លាំង ដែលធ្វើឲ្យបន្ទប់ទទួលបានសីតុណ្ហភាពត្រជាក់ដូចការកំណត់បានលឿនតាមតម្រូវការ។

**PWM (Pulse Width Modulated Wave)**

រក្សាបំរែបំរួលល្បឿន Compressor នៅពេលដែលធានាបានថាបន្ទប់ទទួលបានភាពត្រជាក់ដូចការកំណត់។




**P-TECh* - ថាមពលនៅពីក្រោយ Fast Cooling**

**Compressor** អាចសម្រេចបាននូវភាពត្រជាក់ខ្លាំងបំផុត ក្នុងរយៈពេលដ៏ខ្លីតាំងពីការចាប់ផ្តើមដំបូង។

***P-TECh អនុវត្តលើម៉ូដែល ដែលមានមុខងារ iAUTO-X ។**




**ត្រជាក់រហ័ស និងមានផាសុកភាពជាប់ជានិច្ច**

**PAM** បង្កើនការប្រើប្រាស់ថាមពល ដើម្បីបង្កើនល្បឿន **Compressor** ក្នុងគោលបំណងធ្វើឲ្យត្រជាក់រហ័ស និងមានស្ថេរភាពដូចទៅនឹងកម្រិតសីតុណ្ហភាពដែលបានកំណត់ ដោយមិនខ្ជះខ្ជាយថាមពលអគ្គិសនី ហើយថែមទាំងផ្តល់នូវខ្យល់ត្រជាក់ប្រកបផាសុកភាពជាប់ជានិច្ច។

### មិនមាន INVERTER

ម៉ាស៊ីនត្រជាក់ដែលមិនមាន Inverter អាចប្រតិបត្តិការត្រឹមតែល្បឿនថេរធម្មតាដែលត្រូវការថាមពលខ្លាំងដើម្បីធានាបាននូវកម្រិតសីតុណ្ហភាពដូចការកំណត់។ លើសពីនេះ វាត្រូវបិទនិងបើក Compressor ញឹកញាប់ និងច្រើនដង។ ហេតុដូចនេះ បំរែបំរួលស៊ីតុណ្ហភាពកាន់តែធំ នាំឲ្យខ្ជះខ្ជាយដល់ការប្រើប្រាស់ថាមពលអគ្គិសនីកាន់តែច្រើនផងដែរ។




តាងឲ្យ: ■ ការប្រើប្រាស់ថាមពលអគ្គិសនី — សីតុណ្ហភាព

កំណត់សម្គាល់៖ ខ្ជះខ្ជាយថាមពលអគ្គិសនី ដោយការបិទនិងបើក Compressor ច្រើនដងក្នុងការធានាបាននូវកម្រិតសីតុណ្ហភាពត្រជាក់ដូចការកំណត់។

### INVERTER

ម៉ាស៊ីនត្រជាក់ដែលមាន Inverter ជួយដល់បំរែបំរួលល្បឿន Compressor ដែលផ្តល់នូវដំណើរការជាក់លាក់មួយក្នុងការធានាបាននូវកម្រិតសីតុណ្ហភាពត្រជាក់ដូចការកំណត់។ លើសពីនេះ ម៉ាស៊ីនត្រជាក់ Panasonic Inverter ផ្តល់នូវប្រតិបត្តិការការសន្សំសំចៃថាមពលអគ្គិសនីដ៏ពិសេស ខណៈដែលអាចផ្តល់បានទាំងភាពត្រជាក់ប្រកដោយផាសុកភាពគ្រប់ពេលវេលា។




តាងឲ្យ: ■ ការប្រើប្រាស់ថាមពលអគ្គិសនី — សីតុណ្ហភាព

កំណត់សម្គាល់៖ សន្សំសំចៃថាមពលអគ្គិសនី ដោយបំរែបំរួលល្បឿន Compressor ដើម្បីធានានូវកម្រិតសីតុណ្ហភាពត្រជាក់ដូចការកំណត់។


# ប្រសិទ្ធភាពខ្យល់បរិសុទ្ធស្រស់ថ្លា

R32 REFRIGERANT

ភាពត្រជាក់ប្រកបដោយនិរន្តរភាព

## ភាពត្រជាក់ដែលគ្រប់គ្នាចូលចិត្ត និងមិនប៉ះពាល់ដល់បរិស្ថាន


ការប្រើប្រាស់បច្ចេកវិទ្យាផ្តល់នូវភាពត្រជាក់ដ៏ទំនើបនៅក្នុងប្រព័ន្ធដំណើរការបស់ម៉ាស៊ីនត្រជាក់ គឺដូចជាការរួមចំណែកយ៉ាងខ្លាំងដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការថែរក្សាការបំផ្លាញស្រទាប់អូហ្សូន។ ទាំងនេះបីដូចជាការចូលរួមជួយថែរក្សាបរិស្ថានយើង។

នៅក្រុមហ៊ុន Panasonic យើងប្តេជ្ញាផ្តល់នូវជីវិតរស់នៅប្រកបដោយសុខភាពល្អប្រសើរ និងបានចូលរួមកាត់បន្ថយការបំពុលបរិស្ថានរបស់យើង។ ហេតុនេះហើយ បានជាម៉ាស៊ីនត្រជាក់របស់យើងបំពាក់នូវបច្ចេកវិទ្យាទំនើបជួយថែរក្សាបរិស្ថានកាន់តែច្រើនជាមួយបច្ចេកវិទ្យាទំនើបផ្តល់នូវភាពត្រជាក់ R32។

R32 បច្ចេកវិទ្យាទំនើបផ្តល់នូវភាពត្រជាក់ បង្ហាញឲ្យឃើញគ្រប់វិធីនៃការថ្លៃប្រឌិតខ្ពស់។ វាដំណើរការល្អបំផុតក្នុងការបញ្ជូនកម្តៅមធ្យម ដែលនាំឲ្យការប្រើប្រាស់ថាមពលមានប្រសិទ្ធភាពខ្ពស់ និងជួយកាត់បន្ថយការចំណាយបានច្រើនផងដែរ។ R32 បច្ចេកវិទ្យាទំនើបផ្តល់នូវភាពត្រជាក់ ដែលបញ្ចេញកម្តៅទាបបំផុតទៅផែនដី ហេតុនេះវាជាមិត្តល្អចំពោះបរិស្ថាន។

**HIGHER COOLING CAPACITY**

**R32** អាចបញ្ចេញភាពត្រជាក់កាន់តែល្អបំផុត ដោយការបញ្ចេញកម្តៅចេញមានប្រសិទ្ធភាពខ្ពស់។

**REDUCE ENERGY COSTS**

វាប្រើប្រាស់ថាមពលតិច ជួយដល់ការសន្សំសំចៃលើការចំណាយអគ្គិសនី។

**ECO FRIENDLY**

**R32** ពុំមានផលប៉ះពាល់ទៅលើស្រទាប់អូហ្សូនឡើយ ដូចនេះវាជាមិត្តភាពដ៏ល្អចំពោះបរិស្ថាន។

### លក្ខណៈសម្បត្តិនៃភាពត្រជាក់នៃ R22 R32 និង R410A

| | R-32 | R410A | R-22 |
|---|---|---|---|
| Composition | Single Component | 2 Components | Single Component |
| Chemical Formula | $CH_2F_2$ | $CH_2F_2$ / $CHF_2CF_3$ | $CHCLF_2$ |
| Boiling Point (°C) | -51.7 | -51.5 | -40.8 |
| Ozone Depletion Potential (ODP) | 0 | 0 | 0.055 |
| Global Warming Potential (GWP) | 675 | 2090 | 1810 |
| Pressure | 1.6 x | 1.6 x | 1x |
| Refrigerant Oil | Synthetic Oil (FW50S) | Synthetic Oil (FV50S) | Mineral Oil |
| Toxicity | None | None | None |
| Flammability | A2L Mildly flammable | A1 Non-flammable | A1 Non-flammable |

### តើអ្វីគឺជា R32?

R32 REFRIGERANT

- $CH_2F_2$: Single composition
- $GWP_{R32} \approx \frac{1}{3} GWP_{R410A}$
- Lifetime in atmosphere is shorter, 4 – 9 years
- Ozone Depletion Potential (ODP) = 0
- Non toxic







# ការប្រើប្រាស់យូរអង្វែង

តួម៉ាស៊ីនខាងក្រៅមាំ និងធន់យូរអង្វែង

ការប្រើប្រាស់យូរអង្វែង

## តួម៉ាស៊ីនខាងក្រៅធន់មាំខ្លាំង ធន់នឹងច្រែះ

តួម៉ាស៊ីនត្រជាក់ខាងក្រៅ ផលិតឡើងធន់មាំខ្លាំងសម្រាប់ការប្រើប្រាស់យូរអង្វែងដែលអាចទប់ទល់គ្រប់លក្ខខណ្ឌលំបាកៗ ដើម្បីសម្រេចបាននូវប្រតិបត្តិការដ៏ល្អបំផុត។


**Blue Fin Condenser**

- កែច្នៃកាន់តែមាំ និងធន់ជាងមុន
- ការពាររន្ធខ្យល់ ទប់នឹងការបំផ្លាញពីទឹក ខ្យល់ និងសំណើមផ្សេងៗ
- បង្ការច្រែះ

Blue Fin Condenser

**Copper Tube Condenser**

- បញ្ជូនកម្តៅកាន់តែល្អ
- អាចបញ្ចេញខ្យល់ត្រជាក់កាន់តែខ្លាំង
- ងាយស្រួលក្នុងការសម្អាត និងថែរក្សា

COPPER TUBE CONDENSER

**ការពារមិនឲ្យជ្រាបទឹក PCB**

- ជ័រប្រភេទរេស៊ីនបង្ការការប៉ះពាល់ទៅលើបន្ទះ Printed Circuit Board ( PCB )
- ការពារផលប៉ះពាល់ដែលពាក់ព័ន្ធជាមួយដំណក់ទឹក

**ECO TOUGH***

**Panasonic "ECO TOUCH Casing"**
ផលិតឡើងដើម្បីការប្រើប្រាស់មាំ និងធន់ខ្លាំងដែលមានសមាសធាតុផ្សំនៃ

- ស័ង្កសី
- អាលុយមីញ៉ូម
- ម៉ាញ៉េស្យូម
- ស៊ីលីកូន

ស្រទាប់ការពារនៃថ្នាំកូតនេះមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការកកើតច្រែះ ជាពិសេសលើផ្ទៃរាបស្មើ និងផ្ទៃមុខកាត់។

* អនុវត្តសម្រាប់តែម៉ូដែល X-PREMIUM INVERTER និង PREMIUM INVERTER R32 ប៉ុណ្ណោះ។

ការការពារដ៏ល្អបំផុត

### ការការពារកកើតច្រែះនៅលើផ្ទៃមុខកាត់

សមាសធាតុទាំងអស់នេះរួមផ្សំឡើងដើម្បីការការពារដ៏ល្អបំផុត "របាំងការពារដ៏ល្អបំផុត" ដែលមានប្រសិទ្ធភាពធន់នឹងការកកើតច្រែះបានយ៉ាងល្អ និងជួយទប់ស្កាត់ការរីករាលដាលនៃច្រែះនៅលើផ្ទៃមុខកាត់។



ប្រភេទដាក់ជាប់ជញ្ជាំង៖ ELITE INVERTER Single-Split Type

CS-VU10UKH | CS-VU13UKH | CS-VU18UKH



ឥតប្រើខ្សែ

ប្រើខ្សែ
( ជម្រើស )

## លក្ខណៈសម្បត្តិ

Cooling [ ]: Outdoor Unit

| ម៉ូដែល | | (50Hz) | CS-VU10UKH [CU-VU10UKH] | CS-VU13UKH [CU-VU13UKH] | CS-VU18UKH [CU-VU18UKH] |
|---|---|---|---|---|---|
| អានុភាពត្រជាក់ | (min-max) | kW | 2.80 [0.84-3.28] | 3.66 [0.92-4.20] | 5.20 [1.10-5.80] |
| | (min-max) | Btu/h | 9,550 [2,860-11,200] | 12,500 [3,140-14,300] | 17,700 [3,750-19,800] |
| EER | (min-max) | Btu/hW | 13.64 (12.71-12.44) | 13.59 (12.08-12.43) | 12.21 (12.93-11.86) |
| | (min-max) | W/W | 4.00 (3.73-3.64) | 3.98 (3.54-3.65) | 3.59 (3.79-3.47) |
| ទិន្នន័យអគ្គិសនី | Voltage | V | 220-240 | 220-240 | 220-240 |
| | Current | A | 3.5-3.2 | 4.3-4.0 | 7.0-6.4 |
| | Power Input (min-max) | W | 700 (225-900) | 920 (260-1,150) | 1,450 (290-1,670) |
| បំបាត់សំណើម | | L/h | 1.6 | 2.1 | 2.9 |
| | | Pt/h | 3.4 | 4.4 | 6.1 |
| ចរន្តខ្យល់ | Indoor | $m^3$/min ($ft^3$/min) | 10.2 (360) | 12.3 (435) | 14.8 (520) |
| | Outdoor | $m^3$/min ($ft^3$/min) | 21.6 (760) - 24.9 (880) | 29.0 (1,020) - 30.4 (1,070) | 34.9 (1,230) - 34.9(1,230) |
| កម្រិតរំខាន | Indoor (H / L / Q-Lo) | dB (A) | 36/25/18 | 41/27/19 | 46/36/31 |
| | Outdoor (H) | dB (A) | 47 - 48 | 48 - 49 | 49 - 49 |
| ទំហំ | Height | mm | 306 (511) | 306 (542) | 306 (619) |
| | | inch | 12-1/16 (20-1/8) | 12-1/16 (21-11/32) | 12-1/16 (24-3/8) |
| | Width | mm | 950 (650) | 950 (780) | 950 (824) |
| | | inch | 37-13/32 (25-19/32) | 37-13/32 (30-23/32) | 37-13/32 (32-15/32) |
| | Depth | mm | 280 (230) | 280 (289) | 280 (299) |
| | | inch | 11-1/32 (9-1/16) | 11-1/32 (11-13/32) | 11-1/32 (11-25/32) |
| ទម្ងន់ | Indoor | kg (lb) | 12 (26) | 12 (26) | 12 (26) |
| | Outdoor | kg (lb) | 21 (46) | 29 (64) | 33 (73) |
| អង្កត់ផ្ចិតទុយោ | Liquid Side | mm | ø 6.35 | ø 6.35 | ø 6.35 |
| | | inch | 1/4 | 1/4 | 1/4 |
| | Gas Side | mm | ø 9.52 | ø 12.70 | ø 12.70 |
| | | inch | 3/8 | 1/2 | 1/2 |
| ប្រវែងទុយោ | Chargeless Pipe Length | m | 7.5 | 7.5 | 10.0 |
| | Maximum Pipe Length | m | 20 | 20 | 30 |
| | Maximum Elevation Length | m | 15 | 15 | 20 |
| | Additional Refrigerant Gas* | g/m | 10 | 10 | 15 |
| ការផ្គត់ផ្គង់ថាមពល | | | Indoor | Indoor | Indoor |

*បរិមាណហ្គាសនៅក្នុងម៉ាស៊ីន គឺមានគ្រប់គ្រាន់ហើយ នៅពេលដែលបំពង់ទុយោមិនត្រូវបានបន្តឲ្យវែងជាងប្រវែងទុយោដែលបានកំណត់។

## តេឡេបញ្ជា រចនាឡើងថ្មីសន្លាង

រីករាយជាមួយការរចនាប្រកបដោយភាពច្នៃប្រឌិតថ្មីរបស់តេឡេបញ្ជា Sky Controller ដែលតម្រូវនឹងចុងម្រាមដៃរបស់អ្នកជាមួយនឹងការចុចប៊ូតុងបញ្ជារហ័ស។

ហើយមានគម្របបិទពីលើអាចរុញចុះឡើងមានភាពរអិលល្អ ជាមួយនឹងការបង្ហាញពីជម្រើសជាច្រើនក្នុងការគ្រប់គ្រង និងការកំណត់មុខងារផ្សេងៗ វាក៏ផ្តល់ភាពងាយស្រួល និងសាមញ្ញត្រូវត្រូវនឹងចំណូលចិត្តប្រើប្រាស់។

តេឡ Sky Controller នេះមានទំហំតូចស្រួលកាន់បញ្ជា ខណៈវាមានទទឹង 58.9 មីល្លីម៉ែត្រ និងប្រវែង 164.7 មីល្លីម៉ែត្រតែប៉ុណ្ណោះ។




1. អេក្រង់ LED ងាយស្រួលមើលដំណើរការមុខងារណាមួយ។
2. ប៊ូតុងបិទ/បើក។
3. ចុចបើកដំណើរការមុខងារនៃបច្ចេកវិទ្យា nanoe™ ដើម្បីឲ្យសមាធាតុ nanoe™ X និង nanoe-G ធ្វើការបន្សុទ្ធខ្យល់ និងកម្ចាត់ក្លិនមិនល្អ ទោះបីជាពេលម៉ាស៊ីនត្រជាក់ត្រូវបានបិទក៏ដោយ។
4. បិទ/បើករវាងមុខងារ RADIANT COOLING និង Fast Cooling ( DIRECT )។
5. ចុចចុះ ឬឡើង ដើម្បីកំណត់សីតុណ្ហភាព។
6. មុខងារ IAUTO-X នឹងផ្តល់ខ្យល់ត្រជាក់ទាន់ចិត្តនៅពេលមកដល់ផ្ទះភ្លាមៗនោះ។ បន្ទាប់មករីករាយនឹង មុខងារ RADIANT COOLING ភាពត្រជាក់ស្រស់ស្រាយ ប៉ុន្តែត្រូវចៀសវាងការប្រើខ្យល់ត្រជាក់បាញ់ត្រង់ចំមនុស្ស។
7. កំណត់ចរន្តបាញ់ខ្យល់
8. កំណត់កម្រិតល្បឿនខ្យល់
9. ចុចបិទ/បើក រវាងមុខងារ COOL និង DRY
10. ពន្យារពេលការកំណត់ម៉ោងជាមួយនឹងការគ្រប់គ្រងសីតុណ្ហភាព ដើម្បីការគេងលក់ស្កប់ស្កល់។
11. កំណត់ 24 ម៉ោង ទាំងការកំណត់ម៉ោងបិទ និងបើក។
12. កំណត់ពេលវេលាជាក់ស្តែង ( ម៉ោង និងនាទី )




តេឡេឥតខ្សែ
សម្រាប់ប្រើជាមួយម៉ូដែល ELITE INVERTER

(CS-VU10UKH)

### COOLING MODELS

RADIANT COOLING | SLEEP | mode | nanoeX | nanoe-G | DUST SENSOR | 24 DUAL | (Optional) | 32 (Random) | 20m CS-VU10UKH CS-VU13UKH | 30m CS-VU18UKH

### OUTDOOR

Blue Fin Condenser

R32 REFRIGERANT



CU-VU10UKH

CU-VU13UKH

CU-VU18UKH

ប្រភេទដាក់ជាប់ជញ្ជាំង៖ X-PREMIUM INVERTER Single-Split Type



CS-XU10VKH | CS-XU13VKH

ឥតប្រើខ្សែ

ប្រើខ្សែ
( ជម្រើស )

CS-XU18VKH | CS-XU24VKH

ឥតប្រើខ្សែ

ប្រើខ្សែ
( ជម្រើស )

## លក្ខណៈសម្បត្តិ

Cooling [ ]: Outdoor Unit

| ម៉ូដែល | | (50Hz) | CS-XU10VKH [CU-XU10VKH] | CS-XU13VKH [CU-XU13VKH] | CS-XU18VKH [CU-XU18VKH] | CS-XU24VKH [CU-XU24VKH] |
|---|---|---|---|---|---|---|
| អានុភាពត្រជាក់ | (min-max) | kW | 2.85 (0.84-3.28) | 3.67 (0.92-4.20) | 5.30 (1.10-6.00) | 6.25 (1.12-7.10) |
| | (min-max) | Btu/h | 9,720 (2,860-11,200) | 12,500 (3,140-14,300) | 18,100 (3,750-20,500) | 21,300 (3,820-24,200) |
| EER | (min-max) | Btu/hW | 13.32 (12.71-12.17) | 12.50 (12.08-11.92) | 12.84 (12.93-12.06) | 12.17 (11.94-12.10) |
| | (min-max) | W/W | 3.90 (3.73-3.57) | 3.67 (3.54-3.50) | 3.76 (3.79-3.53) | 3.57 (3.50-3.55) |
| ទិន្នន័យអគ្គិសនី | Voltage | V | 220-240 | 220-240 | 220-240 | 220-240 |
| | Current | A | 3.6-3.3 | 4.7-4.4 | 6.6-6.1 | 8.1-7.5 |
| | Power Input (min-max) | W | 730 (225-920) | 1,000 (260-1,200) | 1,410 (290-1,700) | 1,750 (320-2,000) |
| បំបាត់សំណើម | | L/h | 1.7 | 2.1 | 2.9 | 3.5 |
| | | (Pt/h) | 3.6 | 4.4 | 6.1 | 7.4 |
| ចរន្តខ្យល់ | Indoor | $m^3$/min ($ft^3$/min) | 10.5 (370) | 11.1 (390) | 19.6 (690) | 20.2 (715) |
| | Outdoor | $m^3$/min ($ft^3$/min) | 26.5 (940) - 27.6 (970) | 30.6 (1,080) - 31.4 (1,110) | 34.9 (1,230) - 34.9 (1,230) | 36.0 (1,270) - 36.0 (1,270) |
